# សាក្សី «មានភាពស្ទាក់ស្ទើរ» ក្នុងការឆ្លើយ : ការចោទសួរទៅ ឡុង នរិន្ទ បន្តពីថ្ងៃម្សិលមិញ

*ដោយ គ្រីសស៊ីន អ៊ីវេន*

*ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១១*

*ប្រែសម្រួលដោយ ជា ផល្លា*

សវនាការមេដឹកនាំខ្មែរក្រហម នួន ជា, ខៀវ សំផន និង អៀង សារី បានបន្តទៀតនៅថ្ងៃនេះ ដោយបានចោទសួរទៅកាន់អតីតកម្មាភិបាលខ្មែរក្រហមនៅក្រសួងការបរទេសឈ្មោះ ឡុង នរិន្ទ ស្ទើរពេញមួយថ្ងៃ។ ទោះបីជាសវនាការទាំងមូលដំណើរការទៅមុខរលូនជាងថ្ងៃម្សិលមិញក៏ដោយ ក៏ការសួរសំណួរបន្តទៅកាន់ ឡុង នរិន្ទ បានដំណើរការទៅយ៉ាងយឺតៗដោយសារតែសាក្សីរូបនេះ ទាមទារឲ្យមានការអានសំណួរម្តងទៀតជាច្រើនលើកច្រើនសា។ ពេលដែលសវនាការបញ្ចប់នៅវេលាម៉ោងបួនរសៀលថ្ងៃនេះ អ្នកតាមដានដំណើការម្នាក់ៗហាក់បីដូចជាល្ហើយ ហើយមិនចង់មកកាន់តុលាការនៅថ្ងៃស្អែក ដែលជាថ្ងៃសុក្រចុងសប្តាហ៍ទៀតទេ។

## ការបង្ហាញប្រវត្តិរូបរបស់ ឡុង នរិន្ទ

អង្គសវនាការបានចាប់ផ្តើមដំណើរការយឺត១៥នាទី ដោយសារតែមានបញ្ហាទាក់ទងទៅនឹងខ្សែវីដេអូជាមួយ ឡុង នរិន្ទ។ ចៅក្រម និល ណុន បានជម្រាបទៅគ្រប់ភាគីទាំងអស់ថា តុលាការនឹងបន្តសួរសំណួរទៅសាក្សី ឡុង នរិន្ទ ពេញមួយថ្ងៃសម្រាប់ថ្ងៃនេះ។ ក្រោយមក ចៅក្រម និល ណុន បានជូនដំណឹងទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឲ្យប្រាប់សាក្សី TCW៥៤៧ ត្រឡប់ទៅផ្ទះវិញ ព្រោះសាក្សីរូបនេះ កំពុងតែត្រៀមខ្លួនដើម្បីចូលមកធ្វើសក្ខីកម្មក្នុងករណីដែល ឡុង នរិន្ទ ឈប់មុនកាលកំណត់។ ចៅក្រម និល ណុន និយាយទៀតថា សាក្សី TCW ៥៤៧ នឹងចូលមកធ្វើសក្ខីកម្មនៅខែក្រោយវិញ។

ចៅក្រម និល ណុន បានផ្តល់ឱកាសទៅសហព្រះរាជអាជ្ញារងអន្តរជាតិបន្តការចោទសួរដោយបង្ហាញនូវឯកសារប្រវត្តិរូបរបស់ ឡុង នរិន្ទ ផង។ ចៅក្រមបានស្នើឲ្យសហព្រះរាជអាជ្ញារងបញ្ជាក់លេខកូដឲ្យបានច្បាស់មុននឹងដាក់បញ្ចាំងលើផ្ទាំងក្រណាត់ស។

ក្រោយមក សហព្រះរាជអាជ្ញារងបានជម្រាបទៅតុលាការថា ឯកសារដែលនឹងដាក់បញ្ចាំងជូននេះ គឺជាឯកសារថ្មីដែលទើបតែរកឃើញ ដូច្នេះឯកសារនេះមិនទាន់ដាក់បញ្ចូលនៅក្នុងសំណុំរឿងនៅឡើយទេ។ ក្រោយពីប្រាប់លេខកូដរបស់ឯកសារនេះជាភាសាអង់គ្លេស និងបារាំង រួចហើយសហព្រះ

រាជអាជ្ញារងបាននិយាយថា ឯកសារនេះត្រូវបានថតចម្លងតាមរយៈ Flash Drive និងចែកជូនដល់គ្រប់ភាគីទាំងអស់និងសវនាការទាំងមូលរួចហើយ ។ សហព្រះរាជអាជ្ញារងក៏បានបញ្ជាក់ដែរថា Flash Drive អាចនឹងដំណើរការមិនសូវល្អ ដូច្នេះគាត់បានថតចម្លងជាក្រដាសឯកសារចំនួនបីភាសានិងបានចែកជូនគ្រប់ភាគីទាំងអស់ ។ ក្រោយមកចៅក្រម និល ណុន បានបង្គាប់ទៅតុលាការឲ្យរៀបចំបញ្ចាំងឯកសារលើផ្ទាំងក្រណាត់សដើម្បីឲ្យសាក្សី ឡុង នរិន្ទ អាចមើលឃើញ ។ ការបង្ហាញនេះគឺបង្ហាញតែភាសាខ្មែរប៉ុណ្ណោះ តែភាគីផ្សេងទៀតអាចមើលនៅលើក្រដាសជាភាសាអង់គ្លេស ឬភាសាបារាំង ។

សុន អរុណ មេធាវីប្រឹក្សារបស់ នួន ជា បានស្នើថា ឯកសារថតចម្លងគួរតែចែកជូនទៅគ្រប់ភាគីទាំងអស់ ហើយសម្រាប់ថ្ងៃក្រោយឯកសារទាំងអស់គួរតែចែកជូនគ្រប់ភាគីទាំងអស់ដូចពេលនេះដែរ ។ ការពិភាក្សាគ្នាអំពីឯកសារនេះស៊ីពេលអស់ដប់នាទី ដែលធ្វើឲ្យមេធាវីរបស់ អៀង សារី ឈ្មោះ ម៉ៃខល កាណាវ៉ាស ដែលចាំតែឃ្លាំមើលកម្មវិធីរបស់តុលាការបានស្នើថា ការចែកជូនឯកសារនេះគួរតែធ្វើឡើងមុនសវនាការចាប់ផ្ដើម មិនមែនទើបតែចែកពេលនេះទេ ។ ចៅក្រម និល ណុន យល់ព្រម ហើយបានណែនាំឲ្យភាគីទាំងអស់ត្រៀមឯកសារចែកជូនជាមុន មុននឹងសវនាការចាប់ផ្ដើម ។

សហព្រះរាជអាជ្ញា បានឆ្លើយតបក្នុងលក្ខណៈការពារខ្លួនថា ព្រះរាជអាជ្ញាបាននិយាយប្រាប់មនុស្សម្នាក់នៅក្នុងក្រុមការពារក្ដីរបស់ អៀង សារី រួចហើយកាលពីម្សិលមិញ ហើយក៏បានប្រាប់ពីលេខរបស់ឯកសារនិងអាសយដ្ឋានអ៊ីម៉ែលផងដែរបើសិនជា Flash Drive នោះខូចមិនអាចបើកមើលបាន ។ សហព្រះរាជអាជ្ញារងរូបនេះបានបញ្ជាក់ទៀតថា គាត់បានខិតខំធ្វើកិច្ចការទាំងនោះ ដើម្បីធានាបានថា ភាគីការពារក្ដីមានឯកសារទាំងអស់នោះមុននឹងសវនាការចាប់ផ្ដើម ។ ក្រោយមកសហព្រះរាជអាជ្ញារងបានស្នើទៅតុលាការ ដោយសុំអង្គុយពេលនៅសួរសំណួរ ដើម្បីឲ្យគាត់អាចឃើញមុខសាក្សីតាមកញ្ចក់កំព្យូទ័របានស្រួល ។ ចៅក្រមបានអនុញ្ញាត ។ ដោយសម្លឹងទៅមុខកាមេរ៉ា សហព្រះរាជអាជ្ញាបានធ្វើគារវកិច្ចទៅកាន់សាក្សី ហើយស្នើទៅមន្ត្រីតុលាការឲ្យបញ្ចាំងឯកសារនៅលើផ្ទាំងក្រណាត់ស ។ ព្រះរាជអាជ្ញាបានសួរទៅ ឡុង នរិន្ទ ថាបានចំណាំអក្សររបស់ខ្លួនដែរឬទេ ហើយ ឡុង នរិន្ទ បានឆ្លើយថានៅចាំអក្សររបស់គាត់ ។ ដូចកាលពីម្សិលមិញដែរ បុគ្គលិករបស់អង្គភាពសាក្សី និងអ្នកជំនាញអង្គុយនៅជិតសាក្សី ហើយបុគ្គលិករូបនោះបានស្នើទៅតុលាការថា គាត់មិនឃើញឯកសារនោះទាំងមូលទេ រួចក៏បានប្រាប់តុលាការឲ្យបង្រួមតូចបន្តិច ។ ក្រោយមក សាក្សីបានអានចំណងជើងរបស់ឯកសារនោះ ដែលសរសេរថា “ប្រវត្តិរូបរបស់សមមិត្ត រិទ្ធ” ។

ឡុង នរិន្ទ បាននិយាយថា ឯកសារនេះ គឺជាប្រវត្តិរូបដែលបានធ្វើឡើង«នៅពេលក្រោយមក» ហើយគាត់ក៏បានទទួលស្គាល់ផងដែរថា «រិទ្ធ» គឺជាឈ្មោះបដិវត្តន៍របស់គាត់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទោះពីជា ឡុង នរិន្ទ មិនចាំថ្ងៃខែច្បាស់ពេលដែលគាត់ធ្វើប្រវត្តិរូបនោះក៏ដោយ តែគាត់ចាំថា គាត់ធ្វើប្រវត្តិរូបនោះក្នុងរវាងពីឆ្នាំ១៩៧៥ដល់១៩៧៩។ ក្រោយមក មេធាវីអន្តរជាតិរបស់ ខៀវ សំផន បាននិយាយកាត់សំណួរដោយបញ្ជាក់ថា ការសួរបញ្ជាក់អំពីពីរទំព័រមុខបែបនេះមិនអាចយកជាការ ដើម្បីបញ្ជាក់ពីភាពស្របច្បាប់នៃឯកសារទាំងមូលនោះបានទេ។ ដោយកត់សម្គាល់ឃើញថា អក្សរនៅលើផ្ទាំងក្រណាត់សអានមិនដាច់ ទោះភាសាខ្មែរក្តី មេធាវីរបស់ ខៀវ សំផន បានស្នើទៅតុលាការថា សាក្សីគួរតែទទួលបានឯកសារនោះមុនពេលសវនាការចាប់ផ្តើម។

ចៅក្រម និល ណុន បានសួរទៅ ឡុង នរិន្ទ ថាអក្សរនៅផ្ទាំងក្រណាត់សនេះអានដាច់ឬទេ ឡុង នរិន្ទ បានឆ្លើយថា គាត់ត្រូវការវ៉ែនតាដើម្បីមើលឲ្យច្បាស់។ ក្រោយមក បុគ្គលិករបស់អង្គភាពសាក្សីនិងអ្នកជំនាញបានយកវ៉ែនតាមកឲ្យគាត់ពាក់ តែគាត់និយាយថាគាត់ចង់ពាក់វ៉ែនតានៅក្នុងហោប៉ៅអាវដែលព្យួរក្នុងបន្ទប់មួយទៀតវិញ។ ក្រោយពីចំណាយពេលបន្តិច វ៉ែនតានោះក៏បានរកឃើញ តែបុគ្គលិករបស់អង្គភាពសាក្សីនិងអ្នកជំនាញបានបញ្ជាក់ថា គាត់ និង ឡុង នរិន្ទ នៅតែមើលឯកសារនោះមិនឃើញដដែល ហើយថាគាត់និងអាចមើលឃើញបើសិនជាពង្រីកតែកន្លែងណាដែលចង់ឲ្យសាក្សីអានបានហើយ។ សហព្រះរាជអាជ្ញាបានជូនដំណឹងទៅតុលាការថា ខ្លួននឹងពង្រីកកន្លែងណាដែលចង់ឲ្យសាក្សីឃើញប៉ុណ្ណោះ។ ក្រោយពីមេធាវីរបស់ នួន ជា ជំទាស់មិនឲ្យដាក់បញ្ចាំងឯកសារទាំងនោះ ចៅក្រម និល ណុន បានជូនដំណឹងទៅព្រះរាជអាជ្ញាថា សាក្សីនឹងស្គាល់ច្បាស់ថា ឯកសារនោះ គឺជាប្រវត្តិរូបសរសេរដោយដៃរបស់គាត់។ ក្រោយមក សហព្រះរាជអាជ្ញាបានស្នើថា ខ្លួននឹងបង្ហាញទំព័រនីមួយៗទៅកាន់សាក្សីដើម្បីឲ្យគាត់បញ្ជាក់សាឡើងវិញ។ បន្ទាប់មក សហព្រះរាជអាជ្ញាបានស្នើទៅសាក្សីឲ្យមើលទំព័រនីមួយៗឲ្យច្បាស់សិនមុននឹងរំកិលចុះក្រោមទៀត។ សាក្សីបានបញ្ជាក់ថា ឯកសារនៅលើផ្ទាំងក្រណាត់សនោះ គឺជាអក្សរសរសេរដោយដៃរបស់គាត់។

ក្រោយពីទទួលបានការបញ្ជាក់ពី ឡុង នរិន្ទ ថាឯកសារនោះគឺជាអក្សរសរសេរដៃរបស់គាត់ សហព្រះរាជអាជ្ញាបានស្នើឲ្យគាត់បញ្ជាក់ឲ្យច្បាស់ថា ថាច់ ជា ដែលគាត់បាននិយាយនៅក្នុងឯកសារនោះ គឺជាមនុស្សដូចគ្នានឹង ថាច់ ជា ដែលគាត់រៀនជាមួយឬ។ ឡុង នរិន្ទ បានឆ្លើយដោយអះអាងថា គឺ ថាច់ ជា ហ្នឹងហើយ។ សហព្រះរាជអាជ្ញាបានសួរទៅ ឡុង នរិន្ទ ទៀតថា តើ ថាច់ ជា នោះ គឺជាអនុរដ្ឋមន្ត្រីក្រសួងអប់រំក្នុងរបប លន់ នល់ ឬយ៉ាងណា? ឡុង នរិន្ទ បានឆ្លើយថា កាលពីជំនាន់ លន់ នល់ ថាច់ ជា មានទំនាក់ទំនងជាមួយរដ្ឋាភិបាល តែគាត់មិនបានបញ្ជាក់ពីតួនាទីរបស់

ថាច់ ជា ឲ្យច្បាស់ទេ។ ឡុង នរិន្ទ បានបញ្ជាក់ទៀតថា គាត់មិនច្បាស់ទេថា ថាច់ ជា ត្រូវបានចាប់ជាចំណាប់ខ្មាំងដោយនិស្សិតក្នុងឆ្នាំ១៩៧៨ រួចត្រូវបានសម្លាប់ជាមួយរដ្ឋមន្ត្រីក្រសួងអប់រំប្តុយ៉ាងណាទេ។ ឡុង នរិន្ទ បាននិយាយថា «រឿងកន្លងទៅយូរហើយ» ។

សហព្រះរាជអាជ្ញាបានអានឃ្លាមួយនៅក្នុងឯកសារដែល ឡុង នរិន្ទ សរសេរថា «អាក្បត់ ថាច់ ជា» ។ នៅពេលសួរថាតើហេតុអ្វីបានជានិយាយពាក្យបែបនេះទៅកាន់ ថាច់ ជា ថាជា«អាក្បត់» ឡុង នរិន្ទ បានឆ្លើយថា ការប្រើពាក្យ «អាក្បត់» គឺជាពាក្យ«មិត្តភាព»ទេ។ ក្រោយមក ឡុង នរិន្ទ បានពន្យល់ថា គាត់ត្រូវបានប្រាប់ឲ្យសរសេរពីប្រវត្តិរូបឲ្យលម្អិត និងរៀបរាប់ពីខ្សែបណ្តាញទាក់ទងជាមួយ ថាច់ ជា ដែលត្រូវបានចោទថាជាភ្នាក់ងារសេអ៊ីអា។ ថាច់ ជា បាននិយាយថា «ខ្ញុំដឹងថា ថាច់ ជា គឺជា ភ្នាក់ងារសេ.អ៊ី.អា. ព្រោះគាត់មានទំនាក់ទំនងជាមួយស្ថានទូតជាច្រើន ហើយមាននិន្នាការទៅរកសេ.អ៊ី.អា.ដែរ» ។ បន្ទាប់មក ឡុង នរិន្ទ បាននិយាយថា គាត់ក៏ធ្លាប់ទាក់ទងជាមួយស្ថានទូតដែលជាប្រទេសសង្គមនិយមដែរ តែគាត់មិនមានទំនាក់ទំនងជាមួយសេ.អ៊ី.អា.ទេ។ ដោយមិនដឹងពីហេតុផលនៃការសរសេរប្រវត្តិរូបនេះ ឡុង នរិន្ទ មានជំនឿថា គាត់សរសេរប្រវត្តិរូប ព្រោះអង្គការចង់ដឹងថាតើគាត់មានបានទាក់ទងជាមួយ«ស្ថាប័នណាមួយ»ឬអត់។ ឡុង នរិន្ទ ត្រូវបានប្រាប់ឲ្យសរសេរដោយស្មោះត្រង់ តែគាត់មិនដឹងថា ក្រោយពីសរសេរចប់នឹងមានរឿងអ្វីកើតឡើងទេ។ ក្រោយមកសាក្សីបានសុំទៅបន្ទប់ទឹក ហើយតុលាការរង់ចាំគាត់ត្រឡប់មកវិញ។ ពេលគាត់ត្រឡប់មកវិញ សហព្រះរាជអាជ្ញាបានបន្តទៅទំព័រមួយទៀត តែពេលនោះ សាក្សីបាននិយាយថា អក្សរនៅលើផ្ទាំងក្រណាត់សនោះមើលមិនច្បាស់ទេ។ ក្រោយពីតុលាការពង្រីកឯកសានោះឲ្យជិតបន្តិចមក ទំព័រខាងស្តាំមើលមិនឃើញទេ។ ក្រោយមក ឡុង នរិន្ទ បានអះអាងបញ្ជាក់ថា ឯកសានោះគឺជាអក្សររបស់គាត់។ សហព្រះរាជអាជ្ញាបានអានឯកសារនោះថា «ពេលខ្ញុំកំពុងសិក្សាបណ្តាញទាក់ទងរបស់ខ្ញុំខ្សោយណាស់។ ខ្ញុំធ្លាប់បានទាក់ទងជាមួយអ្នកដែលក្រោយមកក្លាយជាជនក្បត់ និងបានចូលដៃជើងជាមួយជនក្បត់» ។ ឡុង នរិន្ទ ក៏បានសរសេរដែរថា «ជីវិតរស់នៅមិនស្អាតស្អំទេ» ហើយគាត់បានប្រើលុយនិង«រកស៊ី»ដើម្បីចិញ្ចឹមជីវិត។ គាត់ក៏បានសរសេរថា «សីលធម៌ផ្លូវភេទក៏មិនសូវស្អាតស្អំដែរ» ហើយគាត់បាន«អរគុណអង្គការដែលធ្វើឲ្យជីវិតខ្ញុំប្រសើរឡើង» ។

នៅពេលដែលសហព្រះរាជអាជ្ញា សួរថាហេតុអ្វីបានជាគាត់សរសេរឃ្លានោះនៅក្នុងប្រវត្តិរូបសាក្សី ឡុង នរិន្ទ បានបញ្ជាក់ថា គាត់ចង់បង្ហាញដល់បក្សថា «ខ្ញុំមិនមានអ្វីលាក់បាំងអង្គការទេ» ។ គាត់ចង់បង្ហាញពីការស្មោះស្ម័គ្រជាមួយបក្ស និងដើម្បីបង្ហាញថា «ក្រោយពីចូលបដិវត្តន៍ភ្លាម ខ្ញុំកែខ្លួនទាំងស្រុង» ។

ពេលសួរថាហេតុអ្វីក៏និយាយអំពីសីលធម៌ផ្លូវភេទប្រាប់បក្សទៅវិញ ឡុង នរិន្ទ បានឆ្លើយដោយចាកប្រធានថា ពេលគាត់ជាសិស្សគាត់ និងមិត្តរបស់គាត់បែកជាពីរក្រុមគឺ ៖ ក្រុមឆ្វេងនិយម និងក្រុមសេរី ។ គាត់បានអះអាងថា «យើងព្យាយាមបញ្ចុះបញ្ចូលអ្នកផ្សេងឲ្យចូលក្នុងក្រុមរបស់យើងរៀងៗខ្លួន» ។ អ្នកដែលមិនចូល គឺជា«ជនក្បត់» ។ គាត់បានបន្តទៀតថា ក្រុមឆ្វេងនិយមចាត់ទុកខ្លួនឯងថា ជាក្រុមស្អាតស្អំ ចំណែកឯក្រុមសេរី គឺជាក្រុមមិនស្អាតស្អំ ។ នៅពេលសួរថាតើមានរឿងអ្វីកើតឡើងចំពោះអ្នកដែលស្ថិតក្នុងក្រុមមិនស្អាតស្អំ ឬជនក្បត់ ឡុង នរិន្ទ បាននិយាយថា កាលនោះមិនទាន់មានរឿងអ្វីកើតឡើងទេ«នៅពេលនោះ» ទោះបីជាសំណួរនោះមិនមានភាពច្បាស់លាស់ទេថាចង់សំដៅទៅលើសម័យកាលណាក៏ដោយ ។

ក្រោយមក សហព្រះរាជអាជ្ញាបានសួរទៅ ឡុង នរិន្ទ អំពីមនុស្សដែលគាត់រៀបរាប់នៅក្នុងប្រវត្តិរូប ។ ទាក់ទងទៅនឹងមនុស្សម្នាក់ឈ្មោះ សារិន ឆាក សាក្សី ឡុង នរិន្ទ បានឆ្លើយថា សារិន ឆាក គឺជារដ្ឋមន្ត្រីការបរទេសរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ មេធាវីរបស់ ខៀវ សំផន បានកាត់ម្តងទៀត ដោយជូនដំណឹងទៅតុលាការថា តាមឯកសារដែលបានចែកជូនមិនឃើញមានលេខរបស់ឯកសារទេ ដូច្នេះគាត់មានការលំបាកក្នុងការតាមដានណាស់ ។ ចៅក្រម ឡាវែន៍ បានពន្យល់ទៅមេធាវីពីកន្លែងដែលត្រូវរកឯកសារនៅលើទំព័រនីមួយៗ ។ ខណៈពេលមានការកាត់សង្កាក់នេះ ទើបដឹងថា ឡុង នរិន្ទ បានចេញទៅបន្ទប់ទឹកបាត់ទៅហើយ ។

ពេល ឡុង នរិន្ទ ត្រឡប់មកវិញ សហព្រះរាជអាជ្ញាបានរៀបរាប់ឈ្មោះម្នាក់ទៀតនៅក្នុងប្រវត្តិរូបរបស់គាត់គឺ តាប់ សំអាន ។ ឡុង នរិន្ទ បានរៀបរាប់នៅក្នុងឯកសារនោះថា តាប់ សំអាន គឺជាមន្ត្រីទូតប្រហែលជានៅទ្វីបអាហ្វ្រិក ហើយ សំអាន ធ្លាប់ធ្វើការជាមួយ សារិន ឆាក នៅទីក្រុងប៉េកាំង ។ ក្នុងឆ្នាំ១៩៧៦ សំអាត ត្រឡប់មកប្រទេសកម្ពុជាវិញ តែ ឡុង នរិន្ទ មិនគិតថា សំអាន មកធ្វើការនៅក្រសួងការបរទេសក្រោម អៀង សារី ទេ ។ ក្រោយមក សហព្រះរាជអាជ្ញាបានជូនដំណឹងទៅ ឡុង នរិន្ទ ថា សំអាន មានឈ្មោះនៅក្នុងបញ្ជីអ្នកទោសស-២១ ហើយថាអ្នកដែលមានឈ្មោះនៅក្នុងប្រវត្តិរូបរបស់គាត់ទីបញ្ចប់ត្រូវបញ្ជូនទៅមន្ទីរស-២១ ។

ទាក់ទងនឹងឈ្មោះម្នាក់ទៀតនៅក្នុងប្រវត្តិនោះដែរ ឡុង នរិន្ទ បានបញ្ជាក់ថា វ៉ាន់ ពីនី គឺជាមន្ត្រីទូតប្រចាំប្រទេសអេហ្ស៊ីប តែគាត់មិនចាំថា ពីនី ជាមន្ត្រីទូតក្នុងឆ្នាំ១៩៧៦ឬ១៩៧៧ទេ ។ ឡុង នរិន្ទ បានពន្យល់ថា គាត់រៀបរាប់ឈ្មោះ វ៉ាន់ ពីនី នៅក្នុងប្រវត្តិរូប ព្រោះគាត់ត្រូវបានប្រាប់ឲ្យរៀបរាប់ឈ្មោះអ្នកដែលធ្លាប់ធ្វើការជាមួយគាត់នៅទីក្រុងប៉េកាំងក្នុងសម័យរាជរដ្ឋាភិបាលរួបរួមជាតិ ។ នៅពេលសួរថា នរណាជាអ្នកប្រាប់ឲ្យគាត់សរសេរឈ្មោះនៅក្នុងប្រវត្តិរូបនោះ ឡុង នរិន្ទ ហាក់បីដូចជា

ស្ទាក់ស្ទើរមិនចង់ឆ្លើយ ហើយក្រោយមកគាត់បានប្រាប់ថា គ្មាននរណានៅក្រសួងការបរទេសប្រាប់គាត់ឲ្យសរសេរព័ត៌មានទាំងនេះទេ ។

## ព្រះរាជអាជ្ញាព្យាយាមចោទប្រកាន់សាក្សីនៅចំពោះមុខតុលាការ

ដោយសារតែសាក្សីស្ទាក់ស្ទើរ មិនហ៊ានប្រាប់ឈ្មោះអ្នកដែលប្រាប់ឲ្យគាត់រាយឈ្មោះនៅក្នុងប្រវត្តិរូបរបស់គាត់ និងដោយសារតែចម្លើយរបស់សាក្សីរូបនេះមានភាពយឺតយ៉ាវពេក ព្រះរាជអាជ្ញាបាននិយាយថា សាក្សីរូបនេះហាក់បីដូចជាស្ទាក់ស្ទើរមិនចង់ប្រាប់ឈ្មោះ អៀង សារី ដែលជាអតីតមេរបស់ខ្លួន ។ តែសាក្សីរូបនេះបានបដិសេធថាគាត់មិនមានការស្ទាក់ស្ទើរអ្វីទេ ហើយគាត់បានបញ្ជាក់ថា «បើខ្ញុំនឹកឃើញឈ្មោះនោះ ខ្ញុំមិនខ្លាចប្រាប់ទេ» ។

ដោយបញ្ជាក់ថា សហព្រះរាជអាជ្ញានឹងបកស្រាយអំពីទំនាក់ទំនងរវាង ឡុង នរិន្ទ និង អៀង សារី សហព្រះរាជអាជ្ញាបានសួរទៅសាក្សីថាតើគាត់ស្គាល់ អៀង សារី អស់រយៈពេលជាង៤០ឆ្នាំហើយមែនទេ ។ ឡុង នរិន្ទ បានអះអាងថានេះជារឿងត្រឹមត្រូវ ហើយគាត់បានស្គាល់ អៀង សារី តាំងពីពេលដែលគាត់ធ្វើជាបេសកជនពិសេសរបស់រដ្ឋាភិបាលបង្រួបបង្រួមជាតិមកម្ល៉េះ ។ ឡុង នរិន្ទ បានអះអាងថា អៀង សារី គឺជារដ្ឋមន្ត្រីការបរទេសពេលដែលគាត់ធ្វើការនៅទីនោះ ។ តែ ឡុង នរិន្ទ បានបដិសេធថា គាត់មិនមានទំនាក់ទំនងអ្វីជាមួយ អៀង សារី ទេក្រោយឆ្នាំ១៩៧៩ ។

បន្ទាប់មក តុលាការប្រកាសសម្រាក ។

ពេលត្រឡប់មកវិញចៅក្រមបានប្រាប់ថា អង្គជំនុំជម្រះបានផ្ញើឯកសារប្រវត្តិរូបនេះតាមសារអេឡិចត្រូនិចទៅបុគ្គលិករបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញរួចហើយ ដូច្នេះ ឡុង នរិន្ទ អាចមើលឯកសារនោះបានជាមួយបុគ្គលិកគាំពារសាក្សីនិងអ្នកជំនាញ ។ បុគ្គលិកគាំពារសាក្សីនិងអ្នកជំនាញបានជូនដំណឹងទៅតុលាការថា គាត់បានបញ្ជូនសហការីម្នាក់ទៀតទៅហាងហ្វូតូកូពីដើម្បីព្រីនឯកសារទាំងនោះចេញ ហើយថា គាត់នឹងជម្រាបប្រាប់តុលាការវិញ ពេលសហការីនោះយកឯកសារមកដល់ ។ តុលាការបានប្រគល់តួនាទីនេះទៅព្រះរាជអាជ្ញាវិញ ដើម្បីសួរសំណួរបន្តទៅកាន់សាក្សី ។

ព្រះរាជអាជ្ញាក៏បានសួរទៅ ឡុង នរិន្ទ ដើម្បីឲ្យគាត់បញ្ជាក់ឲ្យច្បាស់នូវអ្វីដែលគាត់បាននិយាយមុននឹងសម្រាក ដោយនិយាយថា គាត់មានទំនាក់ទំនងជាមួយ អៀង សារី ឬអត់តាំងពីឆ្នាំ១៩៧៩មក ។ ឡុង នរិន្ទ បានឆ្លើយថា គាត់មិនមានទំនាក់ទំនងជាមួយ អៀង សារី ទេក្រោយឆ្នាំ១៩៧៩នោះ ។ ព្រះរាជអាជ្ញាក៏បានស្នើទៅ ឡុង នរិន្ទ ឲ្យប្រាប់ទៅតុលាការថាអ្វីទៅជាចលនារួបរួមជាតិប្រជាធិបតេយ្យ ។ ឡុង នរិន្ទ បានឆ្លើយថា ចលនារួបរួមជាតិប្រជាធិបតេយ្យ គឺជា«ចលនានយោបាយមួយ» ដែលសមាជិក«បានព្យាយាមអស់ពីសមត្ថភាព ដើម្បីធ្វើឲ្យប្រទេសជាតិរួបរួមគ្នា និងមានកម្លាំង

ខ្លាំង» ។ តែ ឡុង នរិន្ទ បានបញ្ជាក់ថា គាត់គឺជាលេខារបស់ចលនានេះតាំងពីចលនានេះបង្កើតដំបូងមកម្ល៉េះ ហើយថា «មានមនុស្សម្នាក់ទៀត» គឺជាប្រធានចលនារួបរួមជាតិប្រជាធិបតេយ្យនេះ ។ ពេលឈ្លេចសួរបន្តទៀត ឡុង នរិន្ទ បានឆ្លើយថា អៀង សារី គឺជាប្រធានរបស់ចលនានេះ ។ ឡុង នរិន្ទ ទទួលស្គាល់ថា ចលនារួបរួមជាតិប្រជាធិបតេយ្យត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៤ ក្រោយពី អៀង សារី ផ្តាច់ខ្លួនចេញពីមេដឹកនាំខ្មែរក្រហមដទៃទៀត ហើយថា «តាមទ្រឹស្តី» ចលនានេះនៅតែមាននៅឡើយនៅពេលបច្ចុប្បន្ននេះ តែតាម«ការអនុវត្ត»ជាក់ស្តែង ចលនានេះសាបសូន្យហើយ ។ សហព្រះរាជអាជ្ញាបានសួរទៀតថា បើ«តាមទ្រឹស្តី» អៀង សារី នៅជាប្រធានចលនានេះនៅឡើយឬ ។ ឡុង នរិន្ទ បានឆ្លើយថា ចលនារួបរួមជាតិប្រជាធិបតេយ្យនេះ មិនដែលបើកកិច្ចប្រជុំជាក់លាក់ណាមួយទេ ។ ពេលសួរថាតើគាត់មានទំនាក់ទំនងជាមួយ អៀង សារី ទេអំពីចលនានេះ ឡុង នរិន្ទ បានឆ្លើយថា គាត់មិនមានទំនាក់ទំនងជាមួយ អៀង សារី អំពីចលនានេះទេ ។ គាត់មិនដឹងថា អៀង សារី នៅទីណាទេ ។

បន្ទាប់មក បុគ្គលិករបស់អង្គភាពសាក្សី និងអ្នកជំនាញ ដែលបានទៅថតចម្លងប្រវត្តិរូបរបស់សាក្សី បានមកដល់ ហើយការសួរសំណួរបានបញ្ឈប់មួយសន្ទុះ ។ ក្រោយពីឯកសារត្រូវបានប្រគល់ដល់ដៃសាក្សី ឡុង នរិន្ទ រួចហើយ ចៅក្រម និល ណុន បានពន្យល់ប្រាប់ទៅបុគ្គលិករបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញឲ្យបើកទំព័រណា ដែលតុលាការពិភាក្សាទាក់ទងនឹងទំព័រនោះ នៅអំឡុងពេលសួរសំណួរ ។

បន្ទាប់មក សហព្រះរាជអាជ្ញាបានសួរទៅ ឡុង នរិន្ទ ថាហេតុអ្វីបានជាគាត់ត្រូវតែងបានតាំងជាលេខារបស់ចលនារួបរួមជាតិប្រជាធិបតេយ្យនេះ ។ ឡុង នរិន្ទ បាននិយាយថា អៀង សារី គឺជាប្រធានចលនានេះ តែមិនដែលមានកិច្ចប្រជុំអ្វីទេ ។

ស្តាប់មើលទៅហាក់បីដូចជាហត់នឿយ សហព្រះរាជអាជ្ញាបានប្តូរប្រធានបទទៅសួរអំពីថាតើគាត់មានស្គាល់ក្រុមមួយទៀតនៅផ្សារម៉ាឡៃឈ្មោះថា ក្រុមហ៊ុនការិយាល័យពាណិជ្ជកម្មដែរឬទេ ។

ភ្លាមនោះ ម៉ៃខល ការណាវ៉ាស បានជំទាស់ទៅនឹងសំណួរនេះ ដោយស្នើទៅព្រះរាជអាជ្ញាឲ្យប្រាប់ពីចំណុចមួយណានៅក្នុងកថាខណ្ឌរបស់ដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងព័ត៌មាននេះ ។ ព្រះរាជអាជ្ញាបានបញ្ជាក់ថា គាត់គិតថាការពាក់ព័ន្ធគឺ«ជាក់ស្តែងណាស់» ព្រោះសំណួរនេះទាក់ទងនឹងកេរ្តិ៍ឈ្មោះរបស់សាក្សី ឡុង នរិន្ទ ។ ម៉ៃខល ការណាវ៉ាស បានអះអាងទៀតថា សំណួរនេះមិនជាក់ស្តែងទេ ។ ក្រោយមក ចៅក្រម និល ណុន បានឲ្យសហព្រះរាជអាជ្ញាប្រាប់ពីចំណុចនៅក្នុងកថាខណ្ឌរបស់ដីកាដំណោះស្រាយដែលខ្លួនកំពុងសួរនេះ ។ សហព្រះរាជអាជ្ញាបានពន្យល់ថា ខ្លួនព្យាយាមសួរដេញដោល

សាក្សីអំពីបញ្ហានេះ ព្រោះសាក្សីហាក់បីដូចជាស្ទាក់ស្ទើរមិនចង់និយាយទេ ជាពិសេសទាក់ទងនឹង អៀង សារី ។ ព្រះរាជអាជ្ញាបានបញ្ជាក់ទៀតថា ការសួរនេះ គឺដើម្បីចង់ដឹងថាតើ ឡុង នរិន្ទ ហើយ និង អៀង សារី ធ្លាប់នៅអគ្គភាពជាមួយគ្នា ហើយ ឡុង នរិន្ទ មានបំណងមិនចង់បញ្ចេញឈ្មោះ និងចង់លាក់ឈ្មោះ អៀង សារី ។

ម៉ៃខល ការណាវ៉ាស បានឆ្លើយតបវិញថា បើសិនជាសាក្សីពិតជាស្ទាក់ស្ទើរមិនចង់ធ្វើសក្ខីកម្មមែននោះ ដូចច្នេះសាក្សីមិនចាំបាច់ធ្វើសក្ខីកម្មអ្វីទេ ។ តែ ម៉ៃខល ការណាវ៉ាស បានអះអាងថា សាក្សីបានឆ្លើយសំណួរដែលបានសួរមកគាត់ទាំងអស់ ទោះបីជាសុខភាពរបស់គាត់មិនសូវអំណោយផលនិងនៅឆ្ងាយក៏ដោយ ។ ម៉ៃខល ការណាវ៉ាស បានចោទព្រះរាជអាជ្ញាថា "វាយតម្លៃ"សាក្សីហើយ ។ ប្រសិនបើសហព្រះរាជអាជ្ញាមានបំណងបង្ហាញពីភាពលម្អៀងចំពោះសាក្សីនេះ សាក្សីនឹងចោទប្រកាន់ព្រះរាជអាជ្ញាវិញ ។ ម៉ៃខល ការណាវ៉ាស បានបញ្ជាក់ថា មិនគួរសួរសំណួរណាក្រៅទេ ។

តុលាការបានយល់ស្របជាមួយ មេធាវី ការណាវ៉ាស ចំពោះការជំទាស់នេះ ហើយតុលាការបានបញ្ឈប់មិនឲ្យមានការសួរសំណួរបែបនេះទៅកាន់សាក្សី ។ ដោយប្រកាសថា គាត់នឹង"ទទួលយកសំណើរបស់មេធាវី ការណាវ៉ាស" ព្រះរាជអាជ្ញាបានសួរទៅ ឡុង នរិន្ទ ទៀតថាគាត់មានចាំទេថាគាត់ត្រូវបានសម្ភាសដោយមនុស្សម្នាក់ មកពីការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងឆ្នាំ២០០៧ ដែរឬទេ ។ សាក្សីបានឆ្លើយថាគាត់មិនចាំទេ ។ បន្ទាប់មក សហព្រះរាជអាជ្ញាសួរទៅ ឡុង នរិន្ទ ថាតើគាត់មានចាំថា គាត់ទទួលបានឯកសារមួយកាលពីឆ្នាំ២០០៧ដែរឬទេ ឡុង នរិន្ទ បានឆ្លើយថា "ប្រហែលជាមានគេមកសម្ភាសគាត់" តែគាត់មិនចាប់អារម្មណ៍ទេថាតើអ្នកដែលមកនោះ គឺជាអ្នកស៊ើបអង្កេតមកពីតុលាការ ។ ឡុង នរិន ក៏បានអះអាងផងដែរថា គាត់មិនទទួលបានឯកសារអ្វីទេ ។ នៅពេលដែលសួរថាតើពេលសម្ភាសនោះ គាត់និយាយពិតដែរឬទេ ឡុង នរិន បានឆ្លើយថា គាត់បានឆ្លើយដោយក្តីស្មោះត្រង់ ។

សហព្រះរាជអាជ្ញាបានសួរទៀតថាតើគាត់មានឯកសារនេះទេ ។ ពេលនោះបុគ្គលិករបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ដែលនៅជាមួយ ឡុង នរិន្ទ បានឆ្លើយថា គាត់បានបង្ហាញឯកសារនោះទៅ ឡុង នរិន្ទ រួចហើយ និងបានអានឯកសារនោះដែរ ។ ឡុង នរិន្ទ បានអះអាងថា គាត់បានឮពីឯកសារនោះ តែមិនបានចាំទេថាកាលពីសម្ភាសនោះគាត់បាននិយាយដូចម្តេចខ្លះទេ ។ សហព្រះរាជអាជ្ញាបានបង្ហាញទំព័រមួយ ដែលមានហត្ថលេខាដែលបានដាក់បង្ហាញនៅកញ្ចក់អេក្រង់ ដើម្បីបង្ហាញទៅសាក្សីថា គាត់បានផ្តិតមេដៃនៅលើទំព័រនោះ ។ ឡុង នរិន្ទ បានអះអាងបញ្ជាក់ថា ហត្ថលេខានិងស្នាមមេដៃនោះ គឺជារបស់គាត់ពិតមែន ។

ក្រោយពីអានសេចក្តីថ្លែងការណ៍នោះឮៗរួចមក សហព្រះរាជអាជ្ញាបានសួរទៅ ឡុង នរិន្ទ ថា តើពិតឬដែលគាត់ដឹងពីការចាប់ខ្លួនមនុស្សពីរនាក់ក្នុងឆ្នាំ១៩៧៧នោះ។ ឡុង នរិន បានឆ្លើយថា គាត់ដឹងពីការចាប់ខ្លួន សារិន ឆាក និង វ៉ាន់ ពីនី។ សហព្រះរាជអាជ្ញាបានស្នើទៅសាក្សីឲ្យពន្យល់ពីមូលហេតុដែលគាត់និយាយថា គាត់មិនដឹងពីការចាប់ខ្លួននៅក្រសួងការបរទេស។ ឡុង នរិន្ទ បានឆ្លើយថា "ទាល់តែអ្នកនោះបាត់ខ្លួនហើយទើបខ្ញុំដឹងថា អ្នកនោះត្រូវបានចាប់ខ្លួន"។

មេធាវី កាណារ៉ាស បានជំទាស់ម្តងទៀតដែលបានសួរបែបនេះ ហើយគាត់បានទទូចថា សហព្រះរាជអាជ្ញាគួរតែអានកថាខណ្ឌទាំងមូល ព្រោះកថាខណ្ឌនោះបញ្ជាក់ច្បាស់ហើយថា ឡុង នរិន្ទ មិនបាននៅក្នុងអង្គប្រជុំទេនៅពេលដែលមានការចាប់ខ្លួននោះ ហើយថា ឡុង នរិន្ទ ដឹងក្រោយមកទេ បន្ទាប់ពីការចាប់ខ្លួន។ សហព្រះរាជអាជ្ញាបានអះអាងថាខ្លួនគួរតែអានកថាខណ្ឌនីមួយៗម្តងមួយផ្នែកៗបានហើយ ហើយគាត់គ្រោងនឹងធ្វើដូចនេះ។ តុលាការប្រឆាំងនឹងការជំទាស់របស់មេធាវី កាណារ៉ាស ដោយបញ្ជាក់ថា ក្រុមការពារក្តីអាចចោទសួរទៅ ឡុង នរិន្ទ បន្ថែមពីបញ្ហានេះពេលដល់វេនខ្លួនសួរទៅកាន់សាក្សីរូបនេះ។

សហព្រះរាជអាជ្ញាបានសួរទៅ ឡុង នរិន្ទ ថាតើគាត់គិតយ៉ាងម៉េចពេលដែលមានមនុស្សបាត់ខ្លួនពីក្រសួងការបរទេសនោះ។ ឡុង នរិន្ទ បានឆ្លើយថា ដំបូងគាត់គិតថាអ្នកនោះទៅរៀនសូត្រ តែក្រោយមកទើបគាត់ដឹងថាអ្នកនោះត្រូវបានចាប់ខ្លួន។ គាត់បានរៀបរាប់ថា គាត់គិតថា សូម្បីតែអ្នកដែល "ទៅរៀននៅប្រទេសសង្គមនិយម" ក៏ត្រូវចាប់ខ្លួនដែរ។ គាត់និយាយថា "ម្នាក់ៗសុទ្ធតែខ្លាចរៀងៗខ្លួននៅពេលដែលយើងនិយាយពីការទៅរៀនសូត្រ"។

សហព្រះរាជអាជ្ញាបានប្តូរប្រធានបទថ្មីមួយទៀត។ សហព្រះរាជអាជ្ញាបានសួរទៅ ឡុង នរិន្ទ ថាមានបានចូលរួមទេពេលដែល អៀង សារី បង្រៀននយោបាយទៅកម្មាភិបាលនៅក្រសួងការបរទេសនោះ។ ឡុង នរិន្ទ បានឆ្លើយថា វគ្គរៀនសូត្រនៅក្រសួងការបរទេសដឹកនាំដោយ អៀង សារី ហើយគាត់និយាយអំពី "មាគ៌ាបក្ស"។ គាត់និយាយថា អៀង សារី មិននិយាយអំពីការចាប់ខ្លួនកម្មាភិបាលនៅអំឡុងពេលកិច្ចប្រជុំទេ តែគាត់និយាយពីសេ.អ៊ី.អា. និងកា.ហ្សេ.បេ. ហើយ "នរណាៗក៏ញ័រដែរពេលដែល អៀង សារី និយាយពីបញ្ហានេះ"។ ពីមុន ឡុង នរិន្ទ ធ្លាប់និយាយថា អៀង សារី បានប្រាប់គាត់និងកម្មាភិបាលនៅក្រសួងការបរទេសថា មានការចាប់ខ្លួនមនុស្ស។ ដោយមិនឆ្លើយតទៅទៀត ឡុង នរិន្ទ បានសុំទៅបន្ទប់ទឹក។

ពេលគាត់ត្រឡប់មកវិញ សហព្រះរាជអាជ្ញាបានអានផ្នែកដែលពាក់ព័ន្ធនៃអត្ថបទសម្ភាសន៍ម្តងទៀត។ ឡុង នរិន្ទ បានបញ្ជាក់ថា ពេលនេះគាត់នឹកមិនឃើញទេថា អៀង សារី និយាយបែបនេះឬ

យ៉ាងណា តែសាក្សីរូបនេះអះអាងថា គាត់និយាយដោយស្មោះត្រង់ពេលដែលមានអ្នកមកសម្ភាសគាត់លើកមុន ។

ងាកទៅរកប្រវត្តិរូបរបស់ ឡុង នរិន្ទ វិញ សហព្រះរាជអាជ្ញាបានសួរថាតើគាត់ប្រគល់ប្រវត្តិរូបនោះទៅនរណាក្រោយពីសរសេរចប់ ។ ឡុង នរិន្ទ បានឆ្លើយថា គាត់បានប្រគល់ប្រវត្តិរូបនេះទៅប្រធានក្រុមរបស់គាត់ តែថាគាត់មិនដឹងថាគេយកប្រវត្តិរូបនោះទៅធ្វើអ្វីទេ ។

តុលាការសម្រាកអាហារថ្ងៃត្រង់

## បញ្ហានីតិវិធីចាប់ផ្តើមនៅពេលរសៀល

មុនប្រគល់តួនាទីនេះទៅសហព្រះរាជអាជ្ញា ចៅក្រម និល ណុន បាននិយាយទៅកាន់ភាគីទាំងអស់ និងសាធារណជនថា សវនាការនឹងបន្តធ្វើសក្ខីកម្មសាក្សី ឡុង នរិន្ទ ដល់ថ្ងៃស្អែកបន្តទៀត ។ ក្រោយមក ចៅក្រម និល ណុន បានសួរទៅគ្រប់ភាគីថា ព្រះរាជអាជ្ញាត្រូវការពេលវេលាប៉ុន្មានទៀតដើម្បីសួរទៅសាក្សី ។ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងទៅតុលាការថា គាត់មាន១៥នាទីទៀត ចំណែកសហភាគាដែលជាព្រះរាជអាជ្ញាជាតិត្រូវការពេល៣០នាទីដើម្បីសួរ ។ ដោយសារតែសក្ខីកម្មនោះភាគច្រើនទាក់ទងនឹងករណី អៀង សារី ចៅក្រម និន ណុល បានសួរទៅក្រុមរបស់ នួន ជា និង ខៀវ សំផន ថាមានចង់សួរទៅសាក្សីដែរឬអត់ ។ ក្រុមការពារក្តីរបស់ នួន ជា បានឆ្លើយថា ខ្លួនត្រូវការយ៉ាងហោចណាស់ក៏កន្លះម៉ោងដែរដើម្បីសួរ ។ ចំណែកមេធាវីរបស់ អៀង សារី វិញបានឆ្លើយថា ដោយសារតែ ព្រះរាជអាជ្ញានិងភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនទាន់សួរសាក្សីចប់នៅឡើយនោះ គាត់មិនអាចនិយាយនៅពេលនោះទេថាត្រូវការពេលប៉ុន្មានដើម្បីសួរទេ តែគាត់ត្រូវការពេលមិនដល់កន្លះម៉ោងទេ ។

មេធាវីរបស់ អៀង សារី ឈ្មោះ អាង ឧត្តម បានលើកឡើងពីក្តីបារម្ភមួយចំនួនទាក់ទងទៅនឹងឯកសារដែលដាក់បង្ហាញដោយសហព្រះរាជអាជ្ញាកាលពីព្រឹកមិញ ដោយបញ្ជាក់ថា ព្រះរាជអាជ្ញាមិនចង់សំដៅទៅលើលេខពិតប្រាកដនៃទំព័រនីមួយៗទេ ។ ចៅក្រម និល ណុន បានបង្ហាញពីការព្រួយបារម្ភមួយទៀតថា សាក្សីមិនអាចមើលឃើញទិដ្ឋភាពទាំងមូលរបស់សវនាការ ឬក្តអ្វីៗដែលកំពុងលើកឡើងនៅបន្ទប់សវនាការនេះបានទេ ។

ទាក់ទងទៅនឹងចំណុចនេះ ចៅក្រម និល ណុន បានរំឭកទៅគ្រប់ភាគីទាំងអស់ថា ភាគីទាំងអស់ត្រូវតែបញ្ជាក់ពីលេខទំព័រឲ្យបានច្បាស់គ្រប់ភាសាទាំងអស់ ។ ក្តីបារម្ភទាក់ទងទៅនឹងវីដេអូ ចៅក្រម និល ណុន បានសារភាពថា អង្គជំនុំជម្រះមិនមានបទពិសោធន៍ច្រើនជាមួយនឹងការចូលរួមធ្វើសាក្សីពីចម្ងាយបែបនេះទេ ។

ចៅក្រម និល ណុន បានបញ្ជាក់ថា បញ្ហាពិតនោះគឺថាតើសាក្សីនោះឮនូវអ្វីដែលបានសួរឬអត់ ហើយរហូតមកដល់ពេលនេះ មិនទាន់មានបញ្ហាអ្វីចោទជាដុំកំភួន ទាក់ទងនឹងសមត្ថភាពរបស់សាក្សីអំពីការយល់សំណួរដែលបានចោទសួរមកលើគាត់នោះទេ ។ ក្រោយមក សហព្រះរាជអាជ្ញាបានអានលេខឯកសារនោះឲ្យ ឡុង នរិន្ទ ស្តាប់ឡើងវិញ ដោយអានជាបីភាសាតាមសំណើរបស់ក្រុមការពារក្តីរបស់ អៀង សារី ។ ចៅក្រម និល ណុន បានរំឭកទៅគ្រប់ភាគីទាំងអស់ឲ្យមានការប្រុងប្រយ័ត្ន ដោយអានលេខឯកសារទាំងបីភាសារបស់តុលាការពេលដែលបង្ហាញឯកសារណាមួយ ។

## ការប៉ុនប៉ងក្នុងការចោទបន្ត

ដោយចាប់ផ្តើមសួរសំណួរឡើងវិញទៅកាន់សាក្សី សហព្រះរាជអាជ្ញាបានសួរទៅ ឡុង នរិន្ទ ម្តងទៀតថាគាត់មានចាំពេលដែលអ្នកមកពីក្រៅមកចាប់កម្មាភិបាលរបស់ក្រសួងការបរទេសដែរឬអត់ ។ ឡុង នរិន្ទ បានបកស្រាយថា "ក្នុងនាមជាពូជអ្នកចម្បាំង" គាត់មិនចូលរួមពាក់ព័ន្ធជាមួយបញ្ហានេះទេ ហើយថា នរណាដែលចង់ចាប់នរណាម្នាក់នៅក្នុងក្រសួងអាចទៅជួបប្រធានផ្នែកណាមួយ ។ ក្រោយមក សហព្រះរាជអាជ្ញាបានអានអត្ថបទសម្ភាសន៍ដែល ឡុង នរិន្ទ ផ្តល់ឲ្យកាលពីលើកមុនដែលបានរៀបរាប់ថា កម្មាភិបាលមកពីមន្ទីរស-២១មកចាប់មនុស្សនៅក្រសួងការបរទេសផ្ទាល់តែម្តង ។ ឡុង នរិន្ទ បានបន្ថែមទៀតថា គាត់ដឹងព័ត៌មានពីការចាប់ខ្លួនក្រោយពីមនុស្សត្រូវបានចាប់ខ្លួនរួចទៅហើយ ។

ក្រោយមក សហព្រះរាជអាជ្ញាបានសួរទៅ ឡុង នរិន្ទ ថាតើគាត់ចេះប៉ុន្មានភាសា ។ ឡុង នរិន្ទ បានឆ្លើយថា គាត់ចេះភាសាខ្មែរ បារាំង អង់គ្លេសខ្លះៗ និងភាសាឆេក ។ ក្រោយមកសហព្រះរាជអាជ្ញាបានសួរថា តើអាចយល់ពីសំណួរដែលគាត់សួរជាភាសាអង់គ្លេស ដោយមិនចាំបាច់បកប្រែបានទេ ឡុង នរិន្ទ បានឆ្លើយថា គាត់ទទួលបានសញ្ញាបត្រពីសាកលវិទ្យាល័យដែរ តែសញ្ញាបត្រនោះបាត់អស់ហើយព្រោះ«កណ្តៀរស៊ីអស់» ដែលធ្វើឲ្យអ្នកតាមដានដំណើរការសើចកក្អឹកពេលដែលឮ ឡុង នរិន្ទ និយាយបែបនេះ ។

**-ចប់-**